# សុន្ទរកថារបស់
# លោកជំទាវ គីតរ៉ែត គំរង រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម
# ថ្លែងក្នុងឱកាសបើកសិក្ខាសាលា
# ស្តីពី
# "ការផ្សព្វផ្សាយអភិក្រមគ្រប់ដណ្តប់វិស័យពាណិជ្ជកម្ម"

**(Trade SWAp Awareness Workshop)**

**ទីកន្លែង៖ សាកលវិទ្យាល័យកម្ពុជា (UC)**

**កាលបរិច្ឆេទ៖ ថ្ងៃច័ន្ទ ទី០៧ ខែមិថុនា ឆ្នាំ ២០១៦**

- ឯកឧត្តម/លោក...................................តំណាងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យកម្ពុជា ជាទីរាប់អាន!
- លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានកិត្តិយស និងសេចក្តីរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាអធិបតីនៅក្នុងពិធីបើកសិក្ខាសាលាស្តីពី **"ការផ្សព្វផ្សាយអភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម"** ដ៏មានសារៈសំខាន់នេះ នៅឯសាកលវិទ្យាល័យកម្ពុជា ដែលជាគ្រឹះស្ថានឧត្តមសិក្សាដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា ក្នុងនាមឯកឧត្តម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិត ដែលបានអញ្ជើញមកចូលរួមសិក្ខាសាលាព្រឹកនេះយ៉ាងច្រើនកុះករ។

នាងខ្ញុំសូមជម្រាបថា អភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade Sector Wide Approach) ឬ Trade SWAp គឺជាយន្តការដ៏សំខាន់របស់រាជរដ្ឋាភិបាល ដែលមានគោលបំណងលើកស្ទួយភាពជាម្ចាស់ និងពង្រឹងប្រសិទ្ធភាពជំនួយសម្រាប់ពាណិជ្ជកម្ម (Aid-for-Trade) ដែលផ្តល់តាមរយៈដៃគូអភិវឌ្ឍន៍អន្តរជាតិ។ Trade SWAp បានប្រមូលផ្តុំ និងចងក្រងនូវសកម្មភាពកំណែទម្រង់ជាច្រើន ពាក់ព័ន្ធជាមួយកិច្ចការពាណិជ្ជកម្មទៅជាសសរស្តម្ភចំនួនបី សំដៅអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម ដើម្បីកាត់បន្ថយភាពក្រីក្រ និងជម្រុញកំណើនសេដ្ឋកិច្ចប្រកបដោយចេរភាព។

- <u>សសរស្តម្ភទី ១</u> ៖ កំណែទម្រង់ច្បាប់អន្តរវិស័យ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។
- <u>សសរស្តម្ភទី ២</u> ៖ ពង្រីក និងធ្វើពិពិធកម្មវិស័យនាំចេញរបស់កម្ពុជា ផ្តោតលើផលិតផលអទិភាពក្នុង CTIS។
- <u>សសរស្តម្ភទី ៣</u> ៖ កសាងសមត្ថភាពរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធពាណិជ្ជកម្ម ដើម្បីដឹកនាំចរចារ និងចាត់ចែងរាល់កិច្ចការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម។

ដើម្បីសម្រេចបានគោលដៅទាំងនេះ នៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមបង្កើតនូវកម្មវិធីគាំទ្រកិច្ចអភិវឌ្ឍពាណិជ្ជកម្ម (Trade Development Support Program) ឬ TDSP ឡើង ដោយទទួលបានការគាំទ្រហិរញ្ញវត្ថុជាជំនួយឥតសំណងចំនួន US$១៥,៤៥ លានដុល្លារ ពីម្ចាស់ជំនួយពហុភាគីមានដូចជា សហភាពអឺរ៉ុប,

ភ្នាក់ងារអភិវឌ្ឍអន្តរជាតិដាណឺម៉ាក (DANIDA) និងអង្គការសហប្រជាជាតិអភិវឌ្ឍឧស្សាហកម្ម (UNIDO) ហើយធនាគារពិភពលោក ដើរតួជាអ្នកគ្រប់គ្រងមូលធិនិ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កម្មវិធី TDSP នេះ មានគោលដៅបង្កើនប្រសិទ្ធភាពរាជរដ្ឋាភិបាលក្នុងការតាក់តែង និងអនុវត្តគោលនយោបាយពាណិជ្ជកម្ម និងជម្រុញការអនុវត្ត Trade SWAp។ ស្របគ្នានេះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) នៃក្រសួងពាណិជ្ជកម្ម ក៏ត្រូវបានជ្រើសរើសជាភ្នាក់ងារប្រតិបត្តិ (Executing Agency) របស់កម្មវិធី និងជាលេខាធិការដ្ឋាននៃ Trade SWAp ដើម្បីដឹកនាំ និងសម្របសម្រួលការងារអនុវត្តគម្រោងប្រចាំថ្ងៃ។ កម្មវិធី TDSP មានគម្រោងចំនួន ២៩ ដែលត្រូវបានអនុវត្តដោយភ្នាក់ងារពាក់ព័ន្ធវិស័យពាណិជ្ជកម្មចំនួន ១៩ មកពីស្ថាប័នសាធារណៈ និងវិស័យឯកជន។

កម្មវិធី TDSP ត្រូវបានអនុវត្តចំនួនជាង ៦ឆ្នាំហើយ។ ឆ្នាំ ២០១៦នេះ ជាឆ្នាំចុងក្រោយនៃការអនុវត្តកម្មវិធី ហើយបច្ចុប្បន្នគម្រោងចំនួន ២០ ត្រូវបានបញ្ចប់ នៅសល់គម្រោងចំនួន ៩ កំពុងតែដំណើរការ ហើយនឹងបញ្ចប់នៅក្នុង ខែសីហាខាងមុខនេះ។ តាមរយៈលទ្ធផលវាយតម្លៃប្រចាំរបស់ដៃគូអភិវឌ្ឍអន្តរជាតិ បានទទួលស្គាល់ថា ការអនុវត្តគម្រោង TDSP ទទួលបានលទ្ធផលគួរជាទីពេញចិត្ត (Satisfactory Level) ចំនួន ៣ ឆ្នាំជាប់ៗគ្នា ហើយគឺជាគម្រោងដែលល្អបំផុត នៅក្នុងចំណោមគម្រោងទាំងអស់ដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា។

តាមរយៈការអនុវត្តកម្មវិធី TDSP បានធ្វើឲ្យរាជរដ្ឋាភិបាល មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំ និងតាក់តែងនូវគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា សំដៅធ្វើសមាហរណកម្មវិស័យពាណិជ្ជកម្ម ចូលទៅក្នុងបណ្តាញផលិតកម្មនៃប្រទេសនៅក្នុងតំបន់ និងលើពិភពលោក។ ការដាក់ចេញនូវកំណែទម្រង់ថ្មីៗរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីជួយអភិវឌ្ឍន៍វិស័យឯកជន ឲ្យក្លាយទៅជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិនាពេលកន្លងមក គឺជាឧទាហរណ៍មួយដែលបង្ហាញប្រសិទ្ធភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។ តាមរយៈកំណែទម្រង់នេះ បានធ្វើឲ្យចំណាត់ថ្នាក់នៃភាពងាយស្រួលក្នុងការធ្វើធុរកិច្ចរបស់កម្ពុជា កើនឡើងចំនួន ៦ខ្ទង់បើប្រៀបធៀបនឹងឆ្នាំ ២០១៤ ពោលគឺបានថយចុះពីលេខរៀងទី ១៣៣ មកនៅត្រឹមលេខ ១២៧ សម្រាប់ឆ្នាំ ២០១៥។ លើសពីនេះចំណាត់ថ្នាក់ស្តីពីសន្ទស្សន៍ប្រតិបិត្តការដឹកជញ្ជូន (Logistic Performance Index) របស់កម្ពុជា ក៏បានថយចុះពីលេខ ១២៣ នៅក្នុងឆ្នាំ ២០១០ មកនៅត្រឹមលេខ ៨៣ ក្នុងឆ្នាំ ២០១៤ ផងដែរ នេះបើតាមរបាយការណ៍របស់ធនាគារពិភពលោក។

**លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតទាំងអស់ជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់! ដែលបានផ្តល់ហិរញ្ញប្បទានដល់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្មនាពេលកន្លងមក ហើយក៏សូមអគុណជាអនេកប្បការដល់មន្ត្រីរាជការ និងជំនាញការទាំងអស់ ដែលបានសហការខិតខំបំពេញការងារយ៉ាងយកចិត្តទុកដាក់ ប្រកបដោយស្មារតីទទួលខុសត្រូវ ដើម្បីសម្រេចបាននូវវត្ថុបំណងរបស់កម្មវិធី ព្រមទាំងសមិទ្ធផលសំខាន់ៗជាច្រើនសម្រាប់វិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច ដែលបានចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជាចំនួន ១% រៀងរាល់ឆ្នាំ។

អាស្រ័យហេតុនេះ ដើម្បីស្វែងយល់ថាតើរាជរដ្ឋាភិបាលបានប្រឹងប្រែងអភិវឌ្ឍវិស័យពាណិជ្ជកម្មយ៉ាងដូចម្តេច និង តើ Trade SWAp និងកម្មវិធី TDSP មានសកម្មភាព និងមានអត្ថប្រយោជន៍បែបណាចំពោះវិស័យពាណិជ្ជកម្ម ក៏ដូចជាវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា? ខ្ញុំសូមឲ្យលោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតដែលមានវត្តមាននៅទីនេះ មេត្តាយកចិត្តទុកដាក់ចូលរួមស្តាប់ និងលើកឡើងរាល់ចម្ងល់នានា ដែលទាក់ទងកម្មវិធី TDSP និង Trade SWAp ដើម្បីជាបច្ច័យទទួលបានពុទ្ធិថ្មីៗបន្ថែមសម្រាប់អភិវឌ្ឍខ្លួនឯង និងកសាងប្រទេសយើងឲ្យកាន់តែរីកចម្រើនដូចប្រទេសជឿនលឿននានាក្នុងពិភពលោក។

នៅពេលនេះ ខ្ញុំសូមប្រកាសបើកសិក្ខាសាលាជាផ្លូវការ និងសូមជូនពរដល់លោកសាស្ត្រាចារ្យ និងប្អូនៗនិស្សិតទាំងអស់ ឲ្យទទួលបានផ្លែផ្កាប្រកបដោយជោគជ័យពីសិក្ខាសាលាថ្ងៃនេះ ។ សូមអរគុណ!